# មេរៀនទី ៥ ៖ ការងារបម្រើ

*អ្នកអាចបង្រៀនមេរៀននេះម្ដងទាំងអស់ ឬបំបែកវាជាផ្នែកខ្លីៗ ។ សូមសម្របសម្រួលមេរៀននេះទៅតាមកាលៈទេសៈនៅក្នុងមូលដ្ឋានរបស់អ្នក និងតាមតម្រូវការតាមអាយុ ព្រមទាំងតាមការយល់ដឹងរបស់គណៈប្រធានកូរ៉ុម ឬថ្នាក់របស់អ្នក ។*

## ព្រះយេស៊ូវគ្រីស្ទបានបង្រៀនយើងពីរបៀបធ្វើការងារបម្រើ

ដើម្បីជួយសមាជិកគណៈប្រធានកូរ៉ុម ឬថ្នាក់ឲ្យមើលទៅព្រះយេស៊ូវគ្រីស្ទជាគំរូរបស់ពួកគេនៅក្នុងការងារបម្រើ អ្នកអាចអញ្ជើញពួកគេឲ្យនិយាយអំពីការបង្រៀន និងគំរូនៃការបម្រើរបស់ទ្រង់ ( សូមមើល លូកា ១០:២៥–៣៧; នីហ្វៃទី៣ ១៧:៥–១០ ) ។ សូមពន្យល់ថា ការងារបម្រើគឺជាការថែទាំដល់នរណាម្នាក់ ដូចដែលព្រះអង្គសង្គ្រោះបានធ្វើ ។ តើនរណាម្នាក់បានធ្វើការណ៍នេះមកកាន់អ្នកនៅពេលណា ហើយតើវាធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងណាដែរ ? តើគំរូរបស់ព្រះគ្រីស្ទអនុវត្តចំពោះកិច្ចខិតខំរបស់យើងដើម្បីធ្វើការងារបម្រើដល់សមាជិកកូរ៉ុម ឬថ្នាក់របស់យើងបានយ៉ាងដូចម្ដេច? ចំពោះមនុស្សដទៃ ?

## យើងអាចធ្វើការងារបម្រើជូនដល់មនុស្សនៅជុំវិញខ្លួនយើងបាន

ដើម្បីជួយសមាជិកគណៈប្រធានឲ្យទទួលបានការបំផុសគំនិតស្ដីពីរបៀបធ្វើការងារបម្រើដល់សមាជិកកូរ៉ុម ឬថ្នាក់របស់ពួកគេ សូមអញ្ជើញពួកគេឲ្យពិភាក្សាគ្នាចំពោះមនុស្សម្នាក់ៗតាមឈ្មោះ ( លេខាអាចទទួលបានបញ្ជីឈ្មោះថ្នាក់មួយមកពីកម្មវិធីឧបករណ៍សមាជិក ឬពីស្មៀនវួដ ) ។ សំណួរខាងក្រោមនេះអាចជួយបាន ៖

- តើអ្នកដឹងអ្វីខ្លះពីពួកគេ ?
- តើពួកគេមានចំណុចខ្លាំង និងឧបសគ្គអ្វីខ្លះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដែលអាចជួយពួកគេបាន ( ឧទាហរណ៍ ក្នុងការបម្រើ សកម្មភាព និងការប្រជុំថ្ងៃអាទិត្យ ) ?

សូមឲ្យសមាជិកគណៈប្រធានពិចារណាផងដែរអំពីរបៀបដែលពួកគេអាចលើកទឹកចិត្តសមាជិកកូរ៉ុម និងថ្នាក់ឲ្យប្រើចំណុចខ្លាំង និងទេពកោសល្យរបស់ពួកគេដើម្បីផ្ដល់ការងារបម្រើដល់មនុស្សដទៃ ទាំងនៅក្នុង និងនៅក្រៅកូរ៉ុម ឬថ្នាក់របស់ពួកគេ ។

សូមអញ្ជើញគណៈប្រធានកូរ៉ុម ឬថ្នាក់ឲ្យធ្វើសកម្មភាពតាមអ្វីដែលពួកគេមានអារម្មណ៍បំផុសគំនិតឲ្យធ្វើ ។ ពួកគេអាចចង់រំឭក និងកែតម្រូវគម្រោងការដែលបានដាក់នៅក្នុងការប្រជុំគណៈប្រធានថ្មីៗបំផុតរបស់ពួកគេ ដើម្បីដាក់បញ្ចូលផែនការថ្មីៗរបស់ពួកគេ ។ សូមប្រាកដថា ពួកគេយល់ថាព័ត៌មានផ្ទាល់ខ្លួនអំពីបុគ្គលណាម្នាក់ដែលបានចែកចាយ គួរតែត្រូវបានរក្សាជាការសម្ងាត់ ។

## ធនធានគាំទ្រ

- *ក្បួនខ្នាតទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* ជំពូក ២១, នៅលើគេហទំព័រ ChurchofJesusChrist.org
- កូរិនថូស ទី២ ៦:៤–៧; ម៉ូសាយ ១៨:៨–៩; គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១០៦
- វីដេអូ « We Are Strong Together »

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2020 by Intellectual Reserve, Inc. All rights reserved. 4/20. ការបកប្រែនៃ *Quorum and Class Presidency Training—Lesson 5.* Cambodian. PD60011123 258. បោះពុម្ពនៅសហរដ្ឋអាមេរិក